# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រដ្ឋបាលខេត្តក្រចេះ**

## សន្និសីទសារព័ត៌មាន

**ស្តីពី “ ភាពជោគជ័យក្នុងរយៈពេល ៥ឆ្នាំកន្លងមក របស់រដ្ឋបាលខេត្តក្រចេះ ”**

**ថ្លែងដោយ ឯកឧត្តម វ៉ា ថន អភិបាល នៃគណៈអភិបាលខេត្តក្រចេះ**

ថ្ងៃអង្គារ ១០កើត ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ត្រូវនឹងថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៣

ទីស្តីការគណៈរដ្ឋមន្ត្រី

- សូមក្រាបថ្វាយបង្គំ សម្តេចព្រះសង្ឃរាជទាំងពីរគណៈ ជាទីគោរពសក្ការៈ!
- សូមក្រាបបង្គំទូលថ្វាយ ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និង សម្តេចព្រះមហាក្សត្រី **នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត !
- សូមគោរព សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត !
- សូមគោរព សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាទីគោរពដ៏ខ្ពង់ខ្ពស់!
- សូមគោរព ឯកឧត្តម **ផៃ ស៊ីផាន** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រធានអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល ជាទីគោរព !
- ឯកឧត្តម លោកជំទាវ លោក លោកស្រី និងបងប្អូនអ្នកសារព័ត៌មានទាំងអស់ ដែលមាន វត្តមាននៅក្នុងអង្គសន្និសីទសារព័ត៌មាននាពេលនេះ ជាទីមេត្រី!
- បងប្អូនប្រជាពលរដ្ឋកំពុងទស្សនាការផ្សាយផ្ទាល់ ជាទីគោរពស្រលាញ់រាប់អាន!

ថ្ងៃនេះ ក្នុងនាមរដ្ឋបាលខេត្តក្រចេះ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំពិតជាមានសេចក្តីសោមនស្សរីករាយ និងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល ដែលបានរៀបចំសន្និសីទសារព័ត៌មានស្តីពី “**ភាពជោគជ័យក្នុងរយៈពេល៥ឆ្នាំកន្លងមក របស់រដ្ឋបាលខេត្តក្រចេះ**” និងសូមថ្លែងអំណរគុណដល់អ្នកសារព័ត៌មានដែលមានវត្តមាននៅទីនេះ ក៏ដូចជាបងប្អូនប្រជាពលរដ្ឋដែលកំពុងទស្សនាការផ្សាយផ្ទាល់នូវសន្និសីទសារព័ត៌របស់រដ្ឋបាលខេត្តនាឱកាសនេះ។

ក្នុងឱកាសដ៏ថ្លៃថ្លានេះ ខ្ញុំបាទសូមក្រាបបង្គំទូលថ្វាយ ប្រគេន និងគោរពជម្រាបជូនអំពីភាពជោគជ័យក្នុងរយៈពេល ៥ឆ្នាំកន្លងមក របស់រដ្ឋបាលខេត្តក្រចេះ ដូចតទៅ៖

**១- ស្ថានភាពទូទៅ ÷**

ខេត្តក្រចេះ ជាខេត្តមួយស្ថិតនៅភាគឦសាននៃប្រទេសកម្ពុជា មានចម្ងាយពីរាជធានីភ្នំពេញ **៣៤០គីឡូម៉ែត្រ** តាមផ្លូវជាតិលេខ៧ កាត់តាមស្រុកស្នួល ចម្ងាយ **២៥០គីឡូម៉ែត្រ** តាមផ្លូវជាតិលេខ ៧៣ កាត់តាមស្រុកឆ្លូង និងចម្ងាយ **២២០គីឡូម៉ែត្រ** តាមផ្លូវទឹកទន្លេមេគង្គ។ ព្រំប្រទល់ខាងត្បូងជាប់ខេត្តត្បូងឃ្មុំ ខាងជើងជាប់ខេត្តស្ទឹងត្រែង ខាងកើតជាប់ខេត្តមណ្ឌលគីរី និងប្រទេសវៀតណាម ខាងលិចជាប់ខេត្តកំពង់ចាម និងខេត្តកំពង់ធំ។ ខេត្តចែកចេញជា **១ក្រុង ៥សង្កាត់** និង **៦ស្រុក ៤៣ឃុំ** ស្មើនឹង **៣២៧ភូមិ** មានផ្ទៃដីសរុប **១១.០៩៤គីឡូម៉ែត្រការេ** ចែកចេញជាពីរតំបន់សំខាន់ៗ ប៉ែកខាងជើងនិងខាងកើតជាតំបន់ខ្ពង់រាបមានព្រៃឈើ និងស្មៅច្រើនប្រភេទ រួមទាំងប្រភេទដីក្រហមអំណោយផលដល់ការចិញ្ចឹមសត្វគោក្របី និងការដាំដុះដំណាំកសិ-ឧស្សាហកម្ម ដូចជា៖ កៅស៊ូ ម្រេច ស្វាយចន្ទី និងដំណាំឈើហូបផ្លែផ្សេងៗ។ល។ រីឯប៉ែកខាងត្បូង និងខាងលិចជាតំបន់ទំនាប និងតំបន់ដីសើមតាមដងទន្លេមេគង្គសំបូរទៅដោយបឹង ព្រែក អូរ ដីល្បាប់ មានជីជាតិអំណោយផលដល់ការចិញ្ចឹមត្រី និងដាំដុះដំណាំស្បៀងដូចជា៖ស្រូវ ពោត សណ្តែក ល្ង។ល។ ពិសេសទៀតទន្លេមេគង្គគឺជាទីជម្រកមច្ឆជាតិជាច្រើនប្រភេទ និងមានសត្វផ្សោតទន្លេមេគង្គដែលជាសត្វមច្ឆជាតិដ៏កម្រកំពុងទាក់ទាញភ្ញៀវទេសចរណ៍ជាតិ-អន្តរជាតិមកទស្សនាកំសាន្តកាន់តែច្រើនឡើងជារៀងរាល់ឆ្នាំ។

ខេត្តមានតំបន់ការពារធនធានធម្មជាតិ **៦កន្លែង** លើផ្ទៃដីសរុប **៤០៤.៨៩៨ហិកតា** ស្ថិតក្នុងភូមិសាស្ត្រស្រុកស្នួល ស្រុកសំបូរ និងស្រុកព្រែកប្រសព្វ មានស្នាក់ការដែនជម្រកសត្វព្រៃ **១១កន្លែង** និងមានមន្ត្រីឧទ្យានុរក្សចំនួន **២៩នាក់** ស្រី **១នាក់**។

ខេត្តមានប្រជាជនសរុប **៤៣៨.៦៤១នាក់** ស្រី **២២១.២៧៤នាក់** ស្មើនឹង **១០០.៦៧៧គ្រួសារ** ដង់ស៊ីតេប្រជាជន **៤០នាក់ក្នុង០១គីឡូម៉ែត្រការេ**។ ខេត្តមានជនជាតិដើមភាគតិចរស់នៅចំនួន ៧រួមមាន៖ ភ្នង កួយ ស្ទៀង ខោញ មិល ថ្មូន និងក្រោល រស់នៅក្នុងស្រុកសំបូរ ស្រុកស្នួល និងស្រុកចិត្របុរី។ ប្រជាពលរដ្ឋជាកសិករចំនួន **៧៩,៦%** មន្ត្រីរាជការ **៣,២%** ឧស្សាហករ-សិប្បករ **0,៤%** ពាណិជ្ជករ **៦,៨%** និងជាសេវាករ **១០%**។ នៅក្នុងឆ្នាំ២០២១ ចំណូលប្រជាពលរដ្ឋ០១នាក់ ស្មើនឹង **១.៣២៥ដុល្លារអាមេរិក** (GDP)។

**២- ការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ**

ក្រោមការដឹកនាំដ៏ឈ្លាសវៃ និងប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** និងការចង្អុលបង្ហាញដឹកនាំ និងជំរុញពី **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** ព្រមទាំងអនុវត្តតាមកម្មវិធីនយោបាយ យុទ្ធសាស្ត្រចតុកោណក្នុងដំណាក់កាលជាបន្តបន្ទាប់ គោលនយោបាយ និងកំណែទម្រង់នានា ក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត ក្រុមប្រឹក្សាក្រុង ស្រុក គណៈអភិបាលក្រុង ស្រុក ក្រុមប្រឹក្សាឃុំ សង្កាត់ មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ និងប្រជាពលរដ្ឋក្នុងខេត្តក្រចេះទាំងមូលបានចូលរួម និងខិតខំបំពេញការងារប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ មានឆន្ទៈមោះមុត ពុះពាររាល់ការលំបាកដោយឈរលើស្មារតីសាមគ្គី សហការ និងចាត់វិធានការយ៉ាងម៉ឺងម៉ាត់ បង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើស ពង្រឹងការអនុវត្តច្បាប់ និងអនុវត្តគោលនយោបាយ

"ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព" យ៉ាងខ្ជាប់ខ្ជួន ធានាបាននូវសន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាព និងរបៀបរៀបរយសង្គមបានល្អប្រសើរ។ ជាក់ស្តែងក្នុងដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ និងការពិនិត្យបញ្ជីឈ្មោះចុះឈ្មោះបោះឆ្នោតឆ្នាំ២០២២ ប្រព្រឹត្តទៅដោយរលូន សេរី ត្រឹមត្រូវ និងយុត្តិធម៌។

**៣- វិស័យកសិកម្ម**

ខេត្តក្រចេះ ដាំដុះដំណាំស្រូវប្រាំង និងស្រូវវស្សាក្នុងឆ្នាំ២០២២ អនុវត្តបានចំនួន **៥៤.៦៨២ហិកតា** ស្មើនឹង **១០១,២៦%** នៃផែនការ **៥៤.០០០ហិកតា** ទទួលបានបរិមាណផលស្រូវសរុប **១៧៨.៨៣៨តោន** ផ្គត់ផ្គង់តម្រូវការគ្រប់គ្រាន់ក្នុងខេត្ត និងសល់ស្រូវនាំចេញចំនួន **៥៧.៥៨០តោន**។ អនុវត្តការដាំដុះដំណាំរួមផ្សំសរុបចំនួន **១០១.១៩៨ហិកតា** ទទួលបានបរិមាណផលសរុបចំនួន **១.៦០១.៨០២តោន**។

សម្រេចបានកាំដាំដុះដំណាំកៅស៊ូសរុបចំនួន **៨៦.៣៧៤ហិកតា** ដំឡូងមីចំនួន **៧៣.៩៨៩ហិកតា** ស្វាយចន្ទីចំនួន **៦៤.៩១៧ហិកតា** ចេកអំបូងលឿងចំនួន **៣.៤៥៥ហិកតា** អំពៅចំនួន **៦០០០ហិកតា** ម៉ៃសាក់ចំនួន **១.៦៥១ហិកតា** និងឈើហូបផ្លែចំនួន **៦៨១ហិកតា**។

ក្នុងនោះក្រុមហ៊ុនមកវិនិយោគសម្បទានដីសេដ្ឋកិច្ចមានចំនួន **៤៨ក្រុមហ៊ុន** លើផ្ទៃដី **១៩៨.៩៧០ ហិកតា** ដាំដុះកៅស៊ូចំនួន **៥៤.៤៤៥ហិកតា** (កៅស៊ូអវិនិយោគ ៤.៤០៦ហិកតា) ដំឡូងមីចំនួន **១.០០០ ហិកតា** ចេកអំបូងលឿងចំនួន **៣.៤៥៥ហិកតា** អំពៅចំនួន **៦.០០០ហិកតា** ម៉ៃសាក់ចំនួន **១.៦៥១ហិកតា** ស្វាយចន្ទីចំនួន **៣.៤៩៧ហិកតា** និងឈើហូបផ្លែចំនួន **៦៨១ហិកតា**។

ការដាំដុះកៅស៊ូជាលក្ខណៈគ្រួសារចំនួន **២៧.៥២៣ហិកតា** ស្វាយចន្ទីចំនួន **៦១.៤១៩ហិកតា** ដំឡូងមី **៧២.៩៩៨ហិកតា** និងដំណាំរួមផ្សំជាច្រើនពាន់ហិកតាថែមទៀត។ ខេត្តមានក្រុមហ៊ុនរោងចក្រកែច្នៃផលិតផលកសិកម្មចំនួន **៣កន្លែង**៖ រោងចក្រផលិតស្ករសចំនួន **១កន្លែង** និងរោងចក្រផលិតម្សៅដំឡូងមីចំនួន **២កន្លែង** ។

ខេត្តមានរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសយូប៊ីអ៊ីស្នួល **១កន្លែង** វិនិយោគលើផ្ទៃដីចំនួន **៨១៧.៨០ ហិកតា** ស្ថិតនៅឃុំ២ធ្នូ ស្រុកស្នួល។ បច្ចុប្បន្នបានសាងសង់រោងចក្រ សហគ្រាស អគារស្នាក់នៅបានចំនួន **៩ទីតាំង** បានដំណើរការផលិតចំនួន **២ក្រុមហ៊ុន** និងកំពុងបន្តសាងសង់រោងចក្រ និងសហគ្រាសអភិវឌ្ឍន៍ចំនួន **៤ក្រុមហ៊ុន** ព្រមទាំងមានក្រុមហ៊ុនចំនួន **៧ថែមទៀត** បានចុះកិច្ចសន្យាដើម្បីវិនិយោគនៅក្នុងតំបន់រដ្ឋបាលសេដ្ឋកិច្ចពិសេសនេះ។ ខេត្តមានផែស្ងួត **១កន្លែង** ស្ថិតក្នុងស្រុកស្នួល ខេត្តក្រចេះ គឺជាកន្លែងដ៏សំខាន់សម្រាប់ចរាចរណ៍ទំនិញ ចេញចូលតាមច្រកទ្វារព្រំដែនអន្តរជាតិត្រពាំងស្រែ។

ខេត្តមានសមាគមក្រូចថ្លុងកោះទ្រង់ក្រចេះ ស្ថិតក្នុងសង្កាត់កោះទ្រង់ ក្រុងក្រចេះ ខេត្តក្រចេះ ត្រូវបានក្រសួងពាណិជ្ជកម្មសហការជាមួយអង្គការពាក់ព័ន្ធចុះបញ្ជីទំនិញសម្គាល់ភូមិសាស្ត្រ និងត្រូវបានសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការនៅខែមិថុនា ឆ្នាំ២០១៨។ ប្រជាពលរដ្ឋចំនួន **៣៦១គ្រួសារ** ដាំដុះក្រូចថ្លុងលើផ្ទៃដីចំនួន **៦៥,៥១ហិកតា** មានដើមក្រូចសរុប **១៣.៧៩០ដើម** ដើមក្រូចទទួលបានផលចំនួន **២.៤៧៤ដើម** ទទួលបានផលក្នុង១ឆ្នាំ ចំនួន **១៤៨.៤៤០ផ្លែ** តម្លៃលក់ក្នុង១ផ្លែចំនួន **១០.០០០រៀល** ទៅ **១៣.០០០រៀល** បច្ចុប្បន្នកំពុងពង្រីកការដាំដុះបន្ថែមទៀត។ សមាគមក្រឡានថ្មគ្រែ ស្ថិតនៅឃុំថ្មគ្រែ ស្រុកចិត្របុរី ខេត្តក្រចេះ ផលិតបាន

ចំនួន **២.៥តោនក្នុង១ថ្ងៃ** តម្លៃលក់ក្នុង ១គីឡូក្រាមចំនួន **៧.០០០រៀល** ទៅ **១០.០០០រៀល** ចែកចាយទូទាំងរាជធានី ខេត្ត។

**៤- វិស័យអប់រំ និងការបណ្តុះបណ្តាលធនធានមនុស្ស**

ខេត្តមានមត្តេយ្យសិក្សា បឋមសិក្សាគ្រប់ភូមិ អនុវិទ្យាល័យគ្រប់ឃុំ សង្កាត់ វិទ្យាល័យគ្រប់ក្រុង ស្រុក ដោយក្រុង ស្រុកមួយចំនួនមានរហូតដល់ **២ទៅ ៣កន្លែង** សរុបជាអគារសិក្សាទូទាំងខេត្តចំនួន **៣៤១កន្លែង** មាន **៧១៨ខ្នង** ស្មើនឹង **២.៧៩២បន្ទប់**។ ខេត្តមានសាកលវិទ្យាល័យរដ្ឋមាន **១កន្លែង** សាកលវិទ្យាល័យ និងវិទ្យាស្ថានឯកជនមាន **២កន្លែង** គ្រឹះស្ថានសិក្សាឯកជនចំនួន **៨កន្លែង** សាលាគរុកោសល្យចំនួន **១កន្លែង** មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈអភិវឌ្ឍន៍ជំនាញ **១កន្លែង** និងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈអភិវឌ្ឍន៍ស្ត្រីចំនួន **១កន្លែង**។ ខេត្តក្រចេះទទួលបានអំណោយដ៏ថ្លៃថ្លារបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** ជាអគារសិក្សាចំនួន **៧៥កន្លែង** សរុប **១០៤ខ្នង** ស្មើនឹង **៦២៧បន្ទប់**។

ក្នុងឆ្នាំសិក្សា២០២១-២០២២ ខេត្តមានសិស្សប្រឡងមធ្យមសិក្សាទុតិយភូមិចំនួន **២.១៥៤នាក់** ស្រី **១.១៤៤នាក់** ប្រឡងជាប់ចំនួន **១.៦៣៥នាក់** ស្រី **៩២០នាក់** ស្មើនឹង **៧៥,៩១%** ទទួលបាននិទ្ទេស A ចំនួន **២៩នាក់** ស្រី **២០នាក់**។

**៥- វិស័យហេដ្ឋារចនាសម្ព័ន្ធ**

-ដោយមានការវិនិយោគសាធារណៈពីរាជរដ្ឋាភិបាល ខេត្តបាននឹងកំពុងបន្តកសាង ពង្រីក ជួសជុល ផ្លូវជាតិ ផ្លូវខេត្ត និងផ្លូវលំជនបទ រួមទាំងស្ពានថ្មធំៗ ដោយធានាបាននូវការធ្វើដំណើរកាន់តែមានភាពងាយស្រួលទៅគ្រប់បណ្តាក្រុង ស្រុក ឃុំ សង្កាត់ និងភូមិ ហើយប្រទាក់ក្រឡាគ្នាដល់ជនបទដាច់ស្រយាល បម្រើសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋក្នុងការទំនាក់ទំនង ការធ្វើដំណើរ និងការដឹកជញ្ជូនកសិផល និងផលិតផលមកកាន់ទីផ្សារបានយ៉ាងឆាប់រហ័ស។

-ខេត្តក្រចេះកំពុងសាងសង់ស្ពានឆ្លងកាត់ទន្លេមេគង្គពីស្រុកចិត្របុរី ទៅស្រុកព្រែកប្រសព្វ ប្រវែង **១.៧៦១ម៉ែត្រ** និងផ្លូវតភ្ជាប់ក្នុងក្រុងក្រចេះ ប្រវែង **៣១,៦៩គីឡូម៉ែត្រ** ដែលបានបើកការដ្ឋានសាងសង់កាលពីថ្ងៃទី២ ខែមករា ឆ្នាំ២០២៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**។

នាពេលខាងមុខ យោងតាមប្រសាសន៍ដ៏ខ្ពង់ខ្ពស់បំផុតរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ថ្លែងក្នុងពិធីបើកការដ្ឋានសាងសង់ស្ពានឆ្លងកាត់ទន្លេមេគង្គខេត្តក្រចេះ និងផ្លូវភ្ជាប់ សម្រាប់ខេត្តក្រចេះឆ្នាំ២០២៣នេះ គឺជាខេត្តត្រូវប៉ាន់ព្រោះបាននូវសមិទ្ធផលជាច្រើននៅមុនពេលចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរនឹងបើកការដ្ឋានសាងសង់ផ្លូវចំនួន **៣ខ្សែ** ដែលជាគម្រោង World Bank ដូចខាងក្រោម៖

១-ផ្លូវជាតិលេខ៧ ប្រវែង **៣១,២៥គីឡូម៉ែត្រ** ពីចំណុចរង្វង់មូលខ្លាស្មុះ សង្កាត់អូរឬស្សី ក្រុងក្រចេះ ទៅឃុំស្វាយជ្រះ ស្រុកស្នួល ខេត្តក្រចេះ។

២-ផ្លូវខេត្តលេខ៣៧៧ ពីរង្វង់មូលព្រាបសទៅទីរួមស្រុកសំបូរ ប្រវែង **៣៥,៥គីឡូម៉ែត្រ** ដែលមានស្ពាន **០៩កន្លែង** ប្រវែងសរុប **៤១៣ម៉ែត្រ**។

៣-ផ្លូវខេត្តលេខ៣៧៧A (ពីសណ្ដាន់-ទៅផ្លូវជាតិលេខ៧) ប្រវែង **១៣,៥គីឡូម៉ែត្រ**។

### ៦- វិស័យសុខាភិបាល

ខេត្តមានការិយាល័យសុខាភិបាលស្រុកប្រតិបត្តិចំនួន **៣កន្លែង** មន្ទីរពេទ្យបង្អែកចំនួន **៥កន្លែង** មណ្ឌលសុខភាពចំនួន **៣៩កន្លែង** និងប៉ុស្តិ៍សុខភាពចំនួន **១៣កន្លែង** កំពុងដំណើរការបម្រើសេវាសុខភាពយ៉ាងល្អប្រសើរជូនប្រជាពលរដ្ឋនៅតាមមូលដ្ឋាន ពិសេសរួមចំណែកការអនុវត្តគោលនយោបាយជាតិគាំពារសង្គម គោលនយោបាយរបបសន្តិសុខសង្គម និងកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីក្រីក្រមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ។ ខេត្តមានអគារសម្រាកព្យាបាលព្រះសង្ឃចំនួន **១កន្លែង** **១ខ្នង** កម្ពស់ **៣ជាន់** ស្មើនឹង **១៣បន្ទប់** និងមានសាលប្រជុំចំនួន១ ស្ថិតក្នុងមន្ទីរពេទ្យបង្អែកខេត្តក្រចេះ ដែលជាអំណោយដ៏ថ្លៃថ្លារបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** ។

លើការងារប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ រដ្ឋបាលខេត្តក្រចេះបានអនុវត្តយ៉ាងម៉ឺងម៉ាត់តាមការណែនាំ និងបទបញ្ជារបស់រាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃ ក្រសួងសុខាភិបាល ក្រសួង-ស្ថាប័នថ្នាក់ជាតិ និងបានដាក់ចេញនូវវិធានការជាបន្តបន្ទាប់ សំដៅបង្ការ និងទប់ស្កាត់ជំងឺកូវីដ-១៩ នៅក្នុងខេត្តបានល្អប្រសើរ។ គិតត្រឹមថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៣ ការចាក់វ៉ាក់សាំងកូវីដ-១៩ ជូនប្រជាពលរដ្ឋអាយុចាប់ពី ៣ឆ្នាំឡើង ក្នុងក្របខ័ណ្ឌទូទាំងខេត្តក្រចេះ សម្រេចដូសទី១ចំនួន **៣៦៩.២១៩នាក់** ស្មើនឹង **១០៥,០៥%** ដូសទី២ ចំនួន **៣៤០.០០៣នាក់** ស្មើនឹង **៩៦,៧៤%** ដូសទី៣ចំនួន **២១០.៧២៥នាក់** ស្មើនឹង **៦១,៩៨%** ដូសទី៤ ចំនួន **៩១.៥២៣នាក់** ស្មើនឹង **៤៣,៤៣%** ដូសទី៥ ចំនួន **២៤.៣១៦នាក់** ស្មើនឹង **២៦,៥៧%** ដូសទី៦ ចំនួន **១.៩៧៦នាក់** ស្មើនឹង **៨.១៣%**។ ខេត្តក្រចេះពុំមានអ្នកឆ្លងជំងឺកូវីដ-១៩ ចាប់ពីថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២២ មក។

### ៧- វិស័យទេសចរណ៍

វិស័យទេសចរណ៍ ខេត្តបាននឹងកំពុងយកចិត្តទុកដាក់ជម្រុញការអភិវឌ្ឍតំបន់រមណីយដ្ឋានទេសចរណ៍ដែលមាននៅក្នុងខេត្តសរុប **២១កន្លែង** ក្នុងនោះរមណីយដ្ឋានវប្បធម៌ប្រវត្តិសាស្ត្រ **០៦កន្លែង** រមណីយដ្ឋានធម្មជាតិ **១១កន្លែង** និងរមណីយដ្ឋានវប្បធម៌ធម្មជាតិ **១កន្លែង** រមណីយដ្ឋានវប្បធម៌កែច្នៃចំនួន **៣កន្លែង** និងមានរមណីយដ្ឋានបម្រុងទុកចំនួន **១កន្លែង**។ ទន្ទឹមនេះ ខេត្តមានធនធានដ៏កម្រគឺសត្វផ្សោតដែលត្រូវបានគ្រប់គ្រង និងអភិរក្ស ដោយបច្ចុប្បន្នមានសត្វផ្សោតរស់នៅប្រមាណ **៨០ក្បាល** ហើយតំបន់នេះត្រូវបានអភិវឌ្ឍន៍ និងរៀបចំជារមណីយដ្ឋានទេសចរណ៍កំពុងទាញយកភ្ញៀវទេសចរជាតិ-អន្តរជាតិមកទស្សនា និងកំសាន្ត ដោយមានកំណើនជារៀងរាល់ឆ្នាំ។ ផ្នែកអាជីវកម្ម សេវាកម្មទេសចរណ៍ ខេត្តមានសណ្ឋាគារ **១៥កន្លែង** ផ្ទះសំណាក់ **៥២កន្លែង** ភោជនីយដ្ឋាន-អាហារដ្ឋាន **១៥៥កន្លែង** សេវាកម្សាន្តមនុស្សពេញវ័យដូចជា៖ ខារ៉ាអូខេចំនួន **២៣កន្លែង** ហាងម៉ាស្សាចំនួន **១១កន្លែង**។ ជាក់ស្តែងក្នុងឆ្នាំ២០២២ ខេត្តទទួលបានភ្ញៀវទេសចរណ៍សរុប **៣៦៣.៩៨២នាក់** ក្នុងនោះភ្ញៀវទេសចរណ៍អន្តរជាតិចំនួន **៧.០៦៥នាក់** និងភ្ញៀវទេសចរណ៍ជាតិ **៣៥៦.៩១៧នាក់**។

### ៨- វិស័យរ៉ែ និងថាមពល

ខេត្តក្រចេះ មានសក្តានុពលលើវិស័យធនធានធម្មជាតិ រ៉ែថ្មក្រានីត ស្ថិតក្នុងភូមិសាស្ត្រស្រុកស្នួល ស្រុកចិត្របុរី និងស្រុកសំបូរ។ ខេត្តមានក្រុមហ៊ុន សហគ្រាស និងអាជីវករដែលធ្វើការរុករករ៉ែចំនួន **៦១ក្រុមហ៊ុន** ស្មើនឹង **៦៥អាជ្ញាបណ្ណ** មាន៖ ក្រុមហ៊ុនសិក្សាស្រាវជ្រាវរ៉ែលោហៈ **៥ក្រុមហ៊ុន** ស្មើនឹង **៦អាជ្ញាបណ្ណ** ក្រុមហ៊ុនអាជីវកម្មរ៉ែមាស **១ក្រុមហ៊ុន** ស្មើនឹង **១អាជ្ញាបណ្ណ** ក្រុមហ៊ុនអាជីវកម្មថ្មក្រានីតអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្មមាន **២៥ក្រុមហ៊ុន** ស្មើនឹង **២៨អាជ្ញាបណ្ណ**។ ក្រុមហ៊ុន និងអាជីវករធ្វើអាជីវកម្មក្រួស ខ្សាច់ ថ្មសំណង់ចំនួន **៨ក្រុមហ៊ុន** ស្មើនឹង **៨អាជ្ញាបណ្ណ**។ អាជីវករ ធ្វីអាជីវកម្មជីកដីចល័តចំនួន **២២អាជីវករ** ស្មើនឹង **២២អាជ្ញាបណ្ណ**។ ជាការចាប់អារម្មណ៍ក្រុមហ៊ុនអាជីវកម្មរ៉ែមាស **១កន្លែង** ស្ថិតនៅក្នុងស្រុកសំបូរ ខេត្តក្រចេះ វិនិយោគិនមកពីសាធារណរដ្ឋប្រជាមានិតចិន សម្រេចបានការចម្រាញ់មាសសុទ្ធចាប់ពីខែតុលា ឆ្នាំ២០២២ រហូតមកដល់ខែមករា ឆ្នាំ២០២៣ នេះ បានចំនួន **៦៧,៥៣គីឡូក្រាម**។

ក្នុងខេត្តក្រចេះអាជ្ញាធរអគ្គិសនីកម្ពុជា បានចេញអាជ្ញាបណ្ណឱ្យអ្នកចែកចាយអគ្គិសនី **៩អាជ្ញាបណ្ណ** រួមមាន៖ អគ្គិសនីក្រចេះ "EDC" **១អាជ្ញាបណ្ណ** ស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់អគ្គិសនីកម្ពុជា និងអគ្គិសនីឯកជនមាន **៨អាជ្ញាបណ្ណ** ត្រូវបានគ្របដណ្តប់លើភូមិចំនួន **២៧៩ភូមិ** ស្មើនឹង ៨៥,៣២% នៃភូមិរដ្ឋបាលសរុបចំនួន **៣២៧ភូមិ**ទូទាំងខេត្ត ដោយដំណើរការ ២៤ម៉ោង។

### ៩- វិស័យធនធានទឹក និងអនាម័យជនបទ

ខេត្តមានប្រព័ន្ធស្រោចស្រពទឹកចំនួន **៧៤ប្រព័ន្ធ** ទំនប់ប្រវែង **៧៤.២៦៥ម៉ែត្រ** ប្រឡាយមេប្រវែង **១៣៦.០៨២ម៉ែត្រ** ប្រឡាយរងប្រវែង **៦១.១៣៦ម៉ែត្រ** សំណង់បង្ហៀរ **៥១កន្លែង** ទ្វារទឹក **៧៨កន្លែង** និងលូ **៣៥២កន្លែង**។ ស្រោចស្រពផ្ទៃដីទូទាំងខេត្តបាន **២៧.៦០៦,៥២ហិកតា** ស្មើនឹង៥១,១២% នៃផែនការ **៥៤.០០០ហិកតា** ដោយគ្របដណ្តប់ទាំងស្រូវប្រាំង និងស្រូវវស្សា។ សហគមន៍កសិករប្រើប្រាស់ទឹក **៧០សហគមន៍** ស្ថានីយ៍ជលសាស្ត្រ **២កន្លែង** និងអាងតម្រងទឹកភ្លៀង **៨ស្ថានីយ៍**។

-ការផ្គត់ផ្គង់ទឹកជនបទសម្រេចបានការសាងសង់អណ្តូងទឹកក្នុងខេត្តចំនួន **១.៥១៩អណ្តូង** ជួសជុលអណ្តូងស្ទះបានចំនួន **១៥២អណ្តូង**។ ក្នុងឆ្នាំ២០២២នេះ មន្ទីរអភិវឌ្ឍន៍ជនបទខេត្តបានសាងសង់អណ្តូងទឹកថ្មីចំនួន **២៤អណ្តូង** អាងត្រង់ទឹកភ្លៀងចំណុះ **១.០៦១លីត្រ** និងស្តារស្រះសហគមន៍ចំនួន **៦៦កន្លែង**។ រហូតមកពេលនេះ អត្រាគ្របដណ្តប់ផ្នែកទឹកស្អាតចំនួន **៨៣%**នៃប្រជាជនសរុបក្នុងខេត្ត និងបានសាងសង់អគារទីតាំងទីទួលសុវត្ថិភាពចំនួន **៥កន្លែង** ដើម្បីត្រៀមអន្តរាគមន៍ជម្លៀសប្រជាពលរដ្ឋទៅកាន់ទីទួលសុវត្ថិភាពក្នុងពេលមានទឹកជំនន់។

-ការលើកកម្ពស់អនាម័យជនបទ ខេត្តបានផ្សព្វផ្សាយ និងជម្រុញការសាងសង់បង្គន់អនាម័យដល់ខ្នងផ្ទះបានចំនួន **៦៨.៩២៦ខ្នងផ្ទះ** សាងសង់បង្គន់អនាម័យចំនួន **៤៤.៨៧៤បង្គន់**។ អត្រាគ្របដណ្តប់ផ្នែកបង្គន់អនាម័យទូទាំងខេត្តមានប្រមាណ **៦៣%**។

### ១០- វិស័យពាណិជ្ជកម្ម និងឧស្សាហកម្ម សិប្បកម្ម :

ខេត្តមានក្រុមហ៊ុនពាណិជ្ជកម្មចំនួន **១២៧ក្រុមហ៊ុន** សាខាក្រុមហ៊ុនចំនួន **៣៨សាខា** សហគ្រាសពាណិជ្ជកម្មចំនួន **១២១សហគ្រាស** និងអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្មមាន **១.៩៩១មូលដ្ឋាន**។ ខេត្តមានផ្សារ

ធំៗរបស់រដ្ឋចំនួន **៧កន្លែង** ផ្សារធំៗរបស់ឯកជនចំនួន **២កន្លែង** ស្តាម៉ាតចំនួន **១០កន្លែង** ផ្សារតូចៗ (ផ្សារក្រមួន) ចំនួន **៤៧កន្លែង**។ ផ្នែកឧស្សាហកម្ម និងសិប្បកម្ម ខេត្តមានសហគ្រាសផលិតទឹកសុទ្ធចំនួន **៤៥កន្លែង** សហគ្រាសផលិតទឹកត្រីទឹកស៊ីអ៊ីវចំនួន **១កន្លែង** សិប្បកម្មឡតដ្ឋក្បឿងចំនួន **២៥កន្លែង** និងសហគ្រាសផលិតទឹកកកអនាម័យចំនួន **១៦កន្លែង**។

**១១-វិស័យធម្មការ និងសាសនាខេត្ត**

ខេត្តក្រចេះ មានវត្តព្រះពុទ្ធសាសនាសរុបចំនួន **១៧៨វត្ត** ក្នុងនោះគណៈធម្មយុត្តិកនិកាយចំនួន **១២វត្ត** គណៈមហានិកាយចំនួន **១៦៦វត្ត** ។ សាលាពុទ្ធិកបឋមសិក្សាចំនួន **១៣កន្លែង** សាលាពុទ្ធិកអនុវិទ្យាល័យចំនួន **០១កន្លែង** ព្រះពុទ្ធសាសនាមហាយានមានស្នាក់ការថ្វាយបង្គំចំនួន **០២កន្លែង**។ សាសនាឥស្លាមមានម៉ាស្ជិទ **៨៣កន្លែង** ស៊ូរ៉ាវ **១២៧កន្លែង** គ្រិស្ទសាសនាមានវិហារ **២១កន្លែង** ស្នាក់ការថ្វាយបង្គំ **០៧កន្លែង** និងសាសនាមហាយានមានវិហារ **០២កន្លែង** ។

**១២-វិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

-បានផ្តល់ដីជូនអតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារចូលនិវត្តន៍ចំនួន **៣៨៨ខ្នងផ្ទះ** (ផ្ទះថ្ម **១00ខ្នង** និងផ្ទះឈើ **២៨៨ខ្នង**)។

-បានផ្តល់ដីសម្បទានសង្គមកិច្ចជូនប្រជាពលរដ្ឋក្រីក្រខ្វះដីលំនៅឋាន និងដីបង្កបង្កើនផលបានចំនួន **៥.៣២៤គ្រួសារ**។

-បានចុះបញ្ជីដីលក្ខណៈជាប្រព័ន្ធចំនួន **១ក្រុង ៣ស្រុក** ក្នុងនោះក្រុងក្រចេះបានបញ្ចប់ការវាស់វែង **១៤.៣៥៨បណ្ណ** ស្រុកចិត្របុរី ស្រុកព្រែកប្រសព្វ និងស្រុកឆ្លូងបានចំនួន **២៨.០០៩បណ្ណ** ក្នុងនោះបណ្ណសម្បទានដីសង្គមកិច្ចបានចំនួន **២.៥៧៧បណ្ណ**។

-បានចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច **០៩សហគមន៍** ក្នុងនោះបានចេញបណ្ណរួចចំនួន **០៤ភូមិ** មានចំនួន **១៣៤បណ្ណ** (ភូមិពន្ទជា និងភូមិអូរកក់ ឃុំអូរគ្រៀង, ភូមិរវៀង និងភូមិត្នោត ឃុំស្រែជិះ) និងបានបញ្ចប់បិទផ្សាយចំនួន **០៥ភូមិ** មានចំនួន **៨២ក្បាលដី** (ភូមិប៉ាក្លែ និងភូមិស្រែឈូក ឃុំរលួសមានជ័យ, ភូមិកំពង់ដំរី ភូមិឥន្ទជ័យ និងភូមិកំពង់ក្បឿង ឃុំបឹងចារ ស្រុកសំបូរ)។

-ការងារដោះស្រាយទំនាស់ដីធ្លី ក្រុមការងារដោះស្រាយវិវាទដីធ្លីចល័តទទួលសំណុំរឿងចំនួន **១៣៩ករណី** ក្នុងនោះ៖ បានសម្រុះសម្រួលដោះស្រាយបញ្ចប់បានចំនួន **៦៥ករណី** ភាគីដើមបណ្តឹងដកពាក្យបណ្តឹងចំនួន **១ករណី** ច្រានចោលពាក្យបណ្តឹងចំនួន **៤៩ករណី** (ជាសមត្ថកិច្ចរបស់តុលាការ) បញ្ជូនទៅថ្នាក់ជាតិដើម្បីបន្តដោះស្រាយចំនួន **៤ករណី** និងកំពុងដោះស្រាយបន្តតាមផែនការចំនួន **២០ករណី**។

-ការដោះស្រាយវិវាទដីធ្លីរបស់គណៈកម្មការសុរិយោដីថ្នាក់ខេត្ត៖ បានទទួលពាក្យបណ្តឹងក្នុងឆ្នាំ ២០២២ ចំនួន **៣ករណី** បានសម្រុះសម្រួល **៣លើក** និង សម្រេចសេចក្តីចំនួន **១ករណី** និងបញ្ជូនទៅគណៈកម្មការសុរិយោដីថ្នាក់ជាតិដោះស្រាយបន្តលើកផែនការដោះស្រាយបន្តចំនួន **២ករណី**។

-ការដោះស្រាយវិវាទដីធ្លីក្រៅយន្តការគណៈកម្មការសុរិយោដីខេត្ត ទទួលពាក្យបណ្តឹងពីថ្នាក់ជាតិចំនួន **៤៩ករណី** បានដោះស្រាយបញ្ចប់ចំនួន **៣២ករណី** បានលើកផែនការដោះស្រាយបន្តក្នុងឆ្នាំ២០២៣ ចំនួន **១៧ករណី**។

-ពាក្យបណ្ដឹងប្ដឹងចូលរដ្ឋបាលខេត្តចំនួន **៥០ករណី** បានដោះស្រាយបញ្ចប់ចំនួន **៣៥ករណី** បានលើកផែនការដោះស្រាយបន្តក្នុងឆ្នាំ២០២៣ ចំនួន **១៥ករណី**។

-ការងារសំណង់បានចេញលិខិតអនុញ្ញាតសាងសង់ **៤៧គម្រោង** ក្នុងនោះចេញដោយរដ្ឋបាលខេត្តចំនួន **២១គម្រោង** និងរដ្ឋបាលក្រុង ស្រុកចំនួន **២៦គម្រោង** មានក្រឡាផ្ទៃសំណង់ **២៩.០៨៦ម៉ែត្រការ៉េ** ដែលមានទុនវិនិយោគប្រមាណ **៩.១៥៧.៣៦០ដុល្លារអាមេរិក**។

**១៣-ការងារអភិវឌ្ឍន៍ក្រុង**

រដ្ឋបាលខេត្តបានអនុវត្តគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធក្នុងទីរួមខេត្ត រួមមាន ៖

-សម្រេចបានការស្ថាបនាសំណង់ជញ្ជាំងច្រាំងទន្លេប្រវែង **២.៥៣៦ម៉ែត្រ**។

-បានរៀបថ្មម៉ាបក្រាលតាមចញ្ចើមផ្លូវមាត់ទន្លេមានចំនួន **១១.១៨៨ម៉ែត្រការ៉េ** ។

-បានតម្លើងបង្គោលភ្លើងបំពាក់អំពូលថ្មី LEDសូឡា លម្អតាមមាត់ទន្លេ និងផ្លូវក្នុងក្រុង និងទីរួមខេត្តចំនួន **៣៤៥បង្គោល**។

-សម្រេចបានការស្ថាបនាវិមានឯករាជ្យ **១កន្លែង**។

-សម្រេចបានការជួសជុល និងស្ថាបនាសំណង់សិល្បការ្យនានានៅក្នុងក្រុងក្រចេះ។

-បានសាងសង់បុស្បុក រូបសំណាក **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា កាលនៅជាកុមារភាពក្មេងវត្ត និងព្រះគ្រូធម្មាចារ្យ គីម ច្រែង** អមដោយសួនច្បារផ្កាគ្រប់ប្រភេទ រួមទាំងការតុបតែងលម្អស្ពានពាមទេរ ស្ថិតនៅភូមិតាលុស ឃុំបុសលាវ ស្រុកចិត្របុរី ខេត្តក្រចេះ។

**១៤-កម្មវិធីជំនួយសង្គមរបស់រាជរដ្ឋាភិបាល"**

-កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារតូចអាយុក្រោម២ឆ្នាំ **ERk-Rbt;ëSTy £ "ÑD [ Cd¾]a 8AA + ° +* មានអ្នកទទួលផលសរុប ១០.៤៦៤នាក់ ក្នុងនោះស្ត្រីចំនួន **៧.៣៤៣នាក់** និងកុមារចំនួន **៣.១២១នាក់** ចំណាយថវិកាសរុប **៤.២៥៧.៦៤០.០០០៛** (បួនបីលាន ពីររយហាសិបប្រាំពីរលាន ប្រាំមួយរយសែសិបពាន់រៀលគត់)។

-កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងពេលប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ មានអ្នកទទួលផលសរុប **២៨.២៥៥គ្រួសារ** ចំណាយថវិកាសរុប **១៥០.៣៧០.៦៨០.០០០រៀល** (មួយរយហាសិបបីលាន បីរយចិតសិបលាន ប្រាំមួយរយប៉ែតសិបពាន់រៀលគត់)។

-ការឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រក្នុងអំឡុងពេលមានសម្ពាធអតិផរណា *(ERk-Rbt;ëSTy § "ÑD[ Cd¾]a 8AA + ° )* មានចំនួន **៧.០៩១គ្រួសារ** ទទួលប្រាក់ឧបត្ថម្ភសរុប **៩៨៣.២១៦.៣០០រៀល** (ប្រាំបួនរយប៉ែតសិបបីលាន ពីររយដប់ប្រាំមួយពាន់ បីរយរៀលគត់)។ ក្នុងនោះអ្នកទទួលផលបានមកបើកប្រាក់ពីបញ្ញរវីងចំនួន **៦.៦២៦គ្រួសារ** ទទួលបានប្រាក់ឧបត្ថម្ភសរុប **៩១៩.២៧៩.៨០០រៀល** (ប្រាំបួនរយដប់ប្រាំបួនលាន ពីររយចិតប្រាំបួនពាន់ ប្រាំបីរយរៀលគត់)។

-ការឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្ររងគ្រោះទឹកជំនន់ **ERk-Rbt;ëSTy § "ÑD[ Cd¾]a 8AA + ° +* មានចំនួន **៨.៦៧០គ្រួសារ** ប្រាក់ឧបត្ថម្ភសរុប **១.៣៤៩.៤០៨.០០០៛** (**មួយបីលាន បីរយសែសិបប្រាំបួនលាន**

**បួនរយប្រាំបីពាន់រៀលគត់**)។ ក្នុងនោះអ្នកទទួលផលបានបើកប្រាក់ពីបញ្ញើរឹងចំនួន **៨.២៨៨គ្រួសារ** ទទួលបានប្រាក់ឧបត្ថម្ភសរុប **១.២៩១.៨២៤.០០០៛** (មួយបីលាន ពីររយកៅសិបមួយលាន ប្រាំបីរយម្ភៃបួនពាន់រៀលគត់)

**១៥ -កិច្ចសហការប្រតិបត្តិការទ្វេភាគីជាមួយខេត្តជាប់ព្រំដែន**

ខេត្តក្រចេះមានព្រំដែនជាប់ខេត្តប៊ិញភឿក នៃសាធារណរដ្ឋសង្គមនិយមវៀតណាមប្រវែង **១០៣,៧ គីឡូម៉ែត្រ** មានច្រកទ្វារព្រំដែន **២កន្លែង** រួមមាន៖ ច្រកទ្វារព្រំដែនអន្តរជាតិត្រពាំងស្រែ និងច្រកទ្វារព្រំដែនទ្វេភាគីជ័យឃ្លាំង ដែលកំពុងបម្រើដល់ការទំនាក់ទំនងកិច្ចសហប្រតិបត្តិការជាអន្តរជាតិ និងទ្វេភាគីកាន់តែល្អប្រសើរជាមួយប្រទេសវៀតណាម។

ខេត្តក្រចេះ ខេត្តប៊ិញភឿក និងខេត្តប៊ិញយឿង នៃសាធារណរដ្ឋសង្គមនិយមវៀតណាម តែងរក្សានូវចំណងសាមគ្គីភាព មិត្តភាព និងកិច្ចសហប្រត្តិបត្តិការ ដោយបានចាត់តាំងប្រតិភូទៅសួរសុខទុក្ខ និងជូនពរគ្នាទៅវិញទៅមក។ បានបញ្ជូនក្រុមយុវជន និងសមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ ទៅបំពេញទស្សនកិច្ចផ្លាស់ប្តូរបទពិសោធគ្នាទៅវិញទៅមក និងកំណត់របបប្រជុំថ្នាក់ខេត្ត ថ្នាក់ស្រុក និងកម្លាំងប្រដាប់អាវុធដើម្បីដោះស្រាយ និងសម្របសម្រួលរាល់កិច្ចការទាំងឡាយបានល្អប្រសើរ។

**១៦ -ការផ្តល់សេវាសាធារណៈជូនដល់ប្រជាពលរដ្ឋ**

-រដ្ឋបាលខេត្តមានអង្គភាពច្រកចេញចូលតែមួយចំនួន **១កន្លែង** ជាក់ស្តែងក្នុងឆ្នាំ២០២២ បានផ្តល់សេវាចំនួន **៤.០៤១សេវា** និងទទួលបានចំណូលសរុបចំនួន **៨៥៧.៤៩៤.១៨០៛** (ប្រាំបីរយហាសិបប្រាំពីរលាន បួនរយកៅសិបបួនពាន់ មួយរយប៉ែតសិបរៀលគត់)។ នៅរដ្ឋបាលក្រុង ស្រុកមានការិយាល័យច្រកចេញចូលតែមួយក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់បានដាក់ឱ្យដំណើរការអនុវត្តការផ្តល់សេវារដ្ឋបាលតាមយន្តការច្រកចេញចូលតែមួយក្នុងក្របខ័ណ្ឌខេត្ត ចាប់តាំងពីថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២២មក។ ក្នុងការផ្តល់សេវាតាមអង្គភាពច្រកចេញចូលតែមួយ ការិយាល័យច្រកចេញចូលតែមួយក្រុង ស្រុក និងតាមយន្តការច្រកចេញតែមួយរដ្ឋបាលឃុំ សង្កាត់ បានអនុវត្តយ៉ាងម៉ត់ចត់ និងមានប្រសិទ្ធភាព។ ឥរិយាបទមន្ត្រីដែលជាអ្នកផ្តល់សេវា និងប្រជាពលរដ្ឋដែលជាអ្នកទទួលសេវា មានសេចក្តីរីករាយរាក់ទាក់រកគ្នា និងអ្នកទទួលសេវាមានទំនុកចិត្តដោយការអនុវត្តមានតម្លាភាព និងឆាប់រហ័ស។

**១៧-ការងារវេទិកាសាធារណៈ**

ក្នុងឆ្នាំ២០២២ ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តបានរៀបចំវេទិកាសាធារណៈចំនួន **១៥ លើក** មានអ្នកចូលរួមសរុប **៣.៤៨៨នាក់** ស្រី **១.៤៧៤នាក់** ទទួលបានសំណើ និងសំណូមពរចំនួន **៧៧ ករណី** ដោះស្រាយបានចំនួន **៤៥ករណី** និងកំពុងសិក្សាដោះស្រាយចំនួន **៣១ករណី** និង **០១ករណីទៀត** ពុំទាន់ដោះស្រាយ។ ចំពោះសំណើ និងសំណូមពរនានារបស់ប្រជាពលរដ្ឋ ត្រូវបានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្ត ក្រុង ស្រុក រដ្ឋបាលខេត្ត និងមន្ទីរ-អង្គភាពជំនាញ បានខិតខំបំភ្លឺ និងដោះស្រាយ រីឯបញ្ហាដែលមិនអាចដោះស្រាយបានតាមសំណូមពររបស់ប្រជាពលរដ្ឋ ដូចជា៖ការស្នើសុំសាងសង់ផ្លូវ ស្ពាន ដែលត្រូវប្រើប្រាស់ថវិកាច្រើន ក្រុមការងារបានឆ្លើយតបជូនប្រជាពលរដ្ឋ ដោយខិតខំរៀបចំដោះស្រាយជាជំហានៗ

ទៅតាមគម្រោងថវិការបស់រដ្ឋបាលខេត្ត ក្រុង ស្រុក មន្ទីរ អង្គភាព និងមូលនិធិឃុំ សង្កាត់ តាមដំណាក់កាលជាបន្តបន្ទាប់។

មុននឹងបញ្ចប់ យើងខ្ញុំទាំងអស់គ្នាជាក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ ព្រះសង្ឃ និងប្រជាពលរដ្ឋក្នុងខេត្តក្រចេះទាំងមូល សូមគោរពថ្លែងអំណរគុណដ៏ខ្ពង់ខ្ពស់បំផុតជូនចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដែលបានខិតខំយកអស់ពីកម្លាំងកាយចិត្ត ពុះពារចាប់តាំងពីការតស៊ូរំដោះប្រទេសជាតិ ដឹកនាំប្រទេសជាតិឱ្យមានសុខសន្តិភាព ស្មើមុខស្មើមាត់នឹងប្រទេសនានាក្នុងពិភពលោក ការដាក់ចេញនូវច្បាប់ លិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ កម្មវិធីកំណែទម្រង់នានា សំដៅស្តារ ជំរុញ និងអភិវឌ្ឍន៍កំណើនសេដ្ឋកិច្ចជាតិជាបន្តបន្ទាប់ ពិសេសការស្វែងរកប្រភពធនធានមកអភិវឌ្ឍន៍នៅក្នុងទឹកដីខេត្តក្រចេះ ដែលប្រើប្រាស់ទាំងថវិការដ្ឋ និងជំនួយពីប្រទេសជាមិត្ត បង្កើតបាននូវសមិទ្ធផលជាច្រើន ពិសេសហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តដូចជាៈ សាលារៀន មន្ទីរពេទ្យ ផ្លូវក្រាលក្រួសក្រហម ផ្លូវបេតុង ស្ពានថ្មធំៗ រួមទាំងសំណង់ប្រព័ន្ធធារាស្ត្រ និងខ្សែបណ្តាញអគ្គិសនី។ល។ ហើយបច្ចុប្បន្ន **សម្តេចតេជោ នាយករដ្ឋមន្ត្រី** បានផ្តល់ទ្រព្យដ៏មហាសាលគឺស្ពានបេតុងឆ្លងកាត់ទន្លេមេគង្គ និងផ្លូវតភ្ជាប់ដែលប្រជាពលរដ្ឋក្នុងខេត្តក្រចេះពុំធ្លាប់បានទទួលក្នុងប្រវត្តិសាស្ត្រ និងមានភ័ព្វសំណាងបានស្ពានឆ្លងកាត់ទន្លេ និងផ្លូវតភ្ជាប់ក្នុងសម័យតេជោដ៏រុងរឿង។ យើងខ្ញុំទាំងអស់គ្នា សូមចារឹកទុកកំណប់ទ្រព្យដ៏អនេកនេះក្នុងក្រអៅបេះដូង និងគោរពអនុវត្តដោយឥតងាករេតាមមាគ៌ាដឹកនាំប្រកបដោយគតិបណ្ឌិត និងឈ្លាសវៃរបស់ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** ព្រមទាំងគាំទ្រ **សម្តេចតេជោ** ជាបេក្ខភាពនាយករដ្ឋមន្ត្រី សម្រាប់អាណត្តិទី៧ ខាងមុខនេះ និងគាំទ្រយ៉ាងពេញទំហឹងចំពោះ **ឯកឧត្តមបណ្ឌិត ហ៊ុន ម៉ាណែត** ជាបេក្ខភាពនាយករដ្ឋមន្ត្រីបន្តវេន នាពេលអនាគត។

ជាទីបញ្ចប់ ទូលព្រះបង្គំខ្ញុំព្រះករុណាខ្ញុំ សូមថ្វាយព្រះពរ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** និង **សម្តេចព្រះវររាជមាតាជាតិខ្មែរ** និងសូមប្រគេនពរសម្តេចព្រះថេរានុថេរៈគ្រប់ព្រះអង្គ និងសូមគោរពជូនពរសម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី និងបងប្អូនកំពុងទស្សនាការផ្សាយផ្ទាល់សន្និសីទសារព័ត៌មាននាពេលនេះ សូមមានសុខភាពល្អបរិបូរណ៍ និងទទួលបានសម្រេចជោគជ័យគ្រប់ភារកិច្ច ដោយសមប្រកបដោយពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ សូមអរព្រះគុណ និងសូមអរគុណ !។

**សូមអរគុណសន្តិភាព អរគុណនយោបាយឈ្នះ ឈ្នះ**